ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានស្រាវជ្រាវនិងនវានុវត្តន៍

OPEN ACCESS

ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម
Cambodian Journal of Education and STEM

## វិចារណកថា ( Editorial )

# យុទ្ធសាស្ត្រក្នុងការជំរុញការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា

### Strategies to Promote Research in Cambodian Higher Education

ហេង គ្រេង[១] សុក សាយ[២] និង ហេង គីមគង់[១,*]

[១]នាយកដ្ឋានស្រាវជ្រាវនិងនវានុវត្តន៍ ក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[២]អគ្គនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[*]និពន្ធនាយកទទួលបន្ទុកឆ្លើយឆ្លង៖ cjes.dsrmoeys@gmail.com

Kreng Heng[1], Say Sok[2], and Kimkong Heng[1,*]

[1]Department of Research and Innovation, Ministry of Education, Youth and Sport, Phnom Penh, Cambodia

[2]Directorate General of Higher Education, Ministry of Education, Youth and Sport, Phnom Penh, Cambodia

[*]Corresponding editor: cjes.dsrmoeys@gmail.com

https://doi.org/10.62219/cjes.2024221

ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា មានការអភិវឌ្ឍថ្មីៗគួរឱ្យកត់សម្គាល់ ជាពិសេសក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ។ ជាក់ស្តែង ក្រសួងអប់រំ យុវជននិងកីឡាបានខិតខំកសាងមូលដ្ឋានគ្រឹះមួយចំនួនធំសម្រាប់ការបង្កើតប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវ តាមរយៈការផ្តល់ថវិកាស្រាវជ្រាវដល់គ្រឹះស្ថានឧត្តមសិក្សា ការសាងសង់ និងជួសជុលបន្ទប់ពិសោធន៍ ការបំពាក់បរិក្ខារ និងឧបករណ៍ស្រាវជ្រាវទំនើបៗ ការអភិវឌ្ឍសមត្ថភាព និងគុណវុឌ្ឍិអ្នកស្រាវជ្រាវ និងការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ។ ក្រសួងក៏បានជំរុញការបោះពុម្ពអត្ថបទស្រាវជ្រាវ ក្នុងទស្សនាវដ្តីស្រាវជ្រាវជាតិ និងអន្តរជាតិ និងបានលើកកម្ពស់ការអនុវត្តសកម្មភាពពាណិជ្ជូបនីយកម្មស្រាវជ្រាវ តាមរយៈការជំរុញការផលិតផលិតផលគំរូ និងផលិតផលស្រាវជ្រាវ ព្រមទាំងការលើកកម្ពស់ការសហការ ឬការផ្សារភ្ជាប់នឹងវិស័យឯកជនក្នុងកិច្ចការស្រាវជ្រាវ និងការប្រើប្រាស់លទ្ធផលស្រាវជ្រាវពីសំណាក់ភាគីពាក់ព័ន្ធផ្សេងៗ ជាពិសេសស្ថាប័នរាជរដ្ឋាភិបាល និងវិស័យឯកជន។ យោងតាម Heng & Heng (2023) ដើម្បីបន្តជំរុញការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា យើងចាំបាច់ត្រូវមានចក្ខុវិស័យ បេសកកម្ម និងគោលនយោបាយស្រាវជ្រាវច្បាស់លាស់ និងត្រូវមានការវិនិយោគច្បាស់លាស់ និងជាយុទ្ធសាស្ត្រទាំងនៅកម្រិតថ្នាក់ជាតិ និងកម្រិតគ្រឹះស្ថានឧត្តមសិក្សា។ ជាការពិតណាស់ ចក្ខុវិស័យ បេសកកម្ម និងគោលនយោបាយស្រាវជ្រាវច្បាស់លាស់ ពិតជាមានសារៈសំខាន់ សម្រាប់ការកំណត់ និងសម្រួចអាទិភាព ទិសដៅស្រាវជ្រាវរបស់ប្រទេសកម្ពុជា និងគ្រឹះស្ថាននីមួយៗ សម្រាប់ការវិនិយោគជាយុទ្ធសាស្ត្រ ដើម្បីសម្រេចចក្ខុវិស័យអភិវឌ្ឍន៍ជាតិ។ គោលនយោបាយស្រាវជ្រាវ ដែលមានលក្ខណៈជាក់ស្តែង និងច្បាស់លាស់ ជាត្រីវិស័យដ៏សំខាន់សម្រាប់បង្ហាញផ្លូវជាប្រព័ន្ធ សម្រាប់ការជំរុញ

ការអភិវឌ្ឍវប្បធម៌ស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា (Heng et al., 2024)។ ជាមួយគ្នានេះដែរ ការវិនិយោគថវិកាជាយុទ្ធសាស្ត្រ និងជាប្រចាំមានសារៈសំខាន់បំផុតសម្រាប់ការអនុវត្តគោលនយោបាយស្រាវជ្រាវ ដោយសារវាជាមូលដ្ឋានគ្រឹះដែលអាចធ្វើឱ្យចក្ខុវិស័យ បេសកកម្ម និងសកម្មភាពយុទ្ធសាស្ត្រ ដែលដាក់ចេញនៅក្នុងគោលនយោបាយស្រាវជ្រាវអាចអនុវត្តទៅបាន។ ដើម្បីលើកកម្ពស់ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា គោលនយោបាយស្រាវជ្រាវខាងលើគួរផ្តោតលើយន្តការគាំទ្រការស្រាវជ្រាវ និងបង្កើតបរិយាកាសដែលអំណោយផលដល់ការស្រាវជ្រាវ។ ក្រៅពីការផ្តល់មូលនិធិស្រាវជ្រាវដែលមានលក្ខណៈប្រកួតប្រជែង ទាំងនៅកម្រិតជាតិ និងគ្រឹះស្ថាន យន្តការគាំទ្រផ្សេងៗទៀតដែលត្រូវចែងលម្អិត អាចមានកម្មវិធីប្រកួតប្រជែងស្នាដៃស្រាវជ្រាវ ការផ្តល់ពានរង្វាន់ស្រាវជ្រាវ ការលើកទឹកចិត្តចំពោះការស្រាវជ្រាវ ដែលមានគុណភាព កម្មវិធីបណ្តុះបណ្តាល ឬមគ្គុទេសក៍ស្រាវជ្រាវ កម្មវិធីអាហារូបករណ៍សម្រាប់អ្នកស្រាវជ្រាវនិងវេទិកាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវជាមួយភាគីពាក់ព័ន្ធ។ល។ (Heng & Heng, 2023)។

ចំពោះការបង្កើតបរិយាកាសដែលអំណោយផលដល់ការស្រាវជ្រាវ យើងត្រូវបង្កើតឱកាសផ្សេងៗដែលគាំទ្រសកម្មភាពស្រាវជ្រាវ ដូចជាការបង្កើតបណ្តាញអ្នកស្រាវជ្រាវ ឬសហគមន៍ស្រាវជ្រាវ និងការបង្កើតថ្នាល ឬវេទិកាសម្រាប់ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ។ លើសពីនេះ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ និងគម្រោងស្រាវជ្រាវ ការវិនិយោគលើការអភិវឌ្ឍធនធានមនុស្សជាប្រចាំ ដើម្បីបង្កើតអ្នកស្រាវជ្រាវថ្មីៗ និងលើកកម្ពស់សមត្ថភាពអ្នកស្រាវជ្រាវជើងចាស់ និងការជ្រើសរើសតម្លើងឋានៈ និងរក្សាទុកអ្នកស្រាវជ្រាវ ក៏មានសារៈសំខាន់ក្នុងការលើកកម្ពស់ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជាផងដែរ។ ជាសង្ខេប ការលើកកម្ពស់ការស្រាវជ្រាវទាមទារការពង្រឹងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវទាំងមូល។ Heng et al. (2023) បានផ្តល់អនុសាសន៍ចំនួន ១០ចំណុច ដើម្បីអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវដ៏រស់រវើកនៅកម្ពុជា។ អនុសាសន៍ទាំងនោះរួមមាន (១) ការអនុវត្តការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ (២) ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពក្នុងការស្រាវជ្រាវ (៣) ការបង្កើតសង្គមវិទ្យាសាស្ត្រ និងការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍ស្រាវជ្រាវ (៤) ការបង្កើតកម្មវិធីប្រកួតប្រជែងស្នាដៃស្រាវជ្រាវកម្រិតជាតិ និងកម្រិតគ្រឹះស្ថាន (៥) ការបង្កើតគេហទំព័រផ្ទុកទិន្នន័យស្រាវជ្រាវសម្រាប់ចងក្រងនិក្ខេបបទបញ្ចប់ការសិក្សា និងប្រវត្តិរូបអ្នកស្រាវជ្រាវ (៦) ការបង្កើតប្រព័ន្ធលើកទឹកចិត្ត ផ្តោតលើការស្រាវជ្រាវ (៧) ការអនុវត្តគម្រោងវិនិយោគ ដើម្បីកែលម្អអនុវិស័យឧត្តមសិក្សា (៨) ការបង្កើត ពង្រឹងគុណភាពនិងការធ្វើលិបិក្រមទស្សនាវដ្តីស្រាវជ្រាវ (៩) ការបង្កើតថ្នាក់បរិញ្ញាបត្រក្នុងទម្រង់ជាកម្មវិធីកិត្តិយស និងថ្នាក់ក្រោយបរិញ្ញាបត្រតាមរយៈការស្រាវជ្រាវ និងពង្រឹងគុណភាពបណ្តុះបណ្តាលថ្នាក់បណ្ឌិត និង (១០) ការអនុវត្តការរៀបចំក្របខណ្ឌគ្រប់គ្រងការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា។

ផ្អែកតាមការសិក្សា និងបទពិសោធន៍កន្លងមក ក្នុងផែនការយុទ្ធសាស្ត្រអប់រំ ២០២៤-២០២៨ កិច្ចការធំៗចំនួន៣ត្រូវបានកំណត់ ដើម្បីលើកកម្ពស់សមត្ថភាពស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា ក្នុងនោះការវិនិយោគលើការបណ្តុះបណ្តាលធនធានមនុស្សកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតជាចំណុចអាទិភាព ដែលជាមូលដ្ឋានក្នុងការបង្កើនចំនួនអ្នកស្រាវជ្រាវនៅកម្ពុជា។ ជាមួយគ្នានេះដែរ ក្រសួងក៏បានផ្តល់មូលនិធិស្រាវជ្រាវដល់អ្នកស្រាវជ្រាវ ជាពិសេសនិស្សិតថ្នាក់បណ្ឌិត ដើម្បីលើកកម្ពស់សកម្មភាពស្រាវជ្រាវ និងការបោះពុម្ពផ្សាយ ជាមួយនឹងការរៀបចំក្របខណ្ឌគ្រប់គ្រងការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សាផងដែរ។ ជាយុទ្ធសាស្ត្រជានានិរន្តរភាពនៃការស្រាវជ្រាវ ការបង្កើតឱ្យមានមូលនិធិបរធនបាលស្រាវជ្រាវ ផ្សារភ្ជាប់នឹងវិស័យឯកជន ជាកិច្ចការចាំបាច់ និងត្រូវបានរំលេចក្នុងផែនការយុទ្ធសាស្ត្រអប់រំផងដែរ ដោយកិច្ចការនេះជាចលករជានាការសម្រេចបាននូវសកម្មភាពគាំទ្រការស្រាវជ្រាវផ្សេងៗ។

សរុបជារួម ដើម្បីលើកកម្ពស់ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា ទាមទារការរៀបចំឱ្យមានប្រព័ន្ធគាំទ្រ និងកសាងអ្នកស្រាវជ្រាវ និងជំរុញសកម្មភាពស្រាវជ្រាវដែលមានដំណើរការជាប្រចាំ ទាំងកម្រិតក្រសួង និងកម្រិតគ្រឹះស្ថានឧត្តមសិក្សា។ ការជំរុញ និងលើកកម្ពស់ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា គឺជាកិច្ចការរួម ដែលទាមទារការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងធ្វើកិច្ចការរួមគ្នា ដើម្បីសម្រេចគោលដៅរួម ក្នុងការជំរុញ និងអភិវឌ្ឍវប្បធម៌ស្រាវជ្រាវដ៏រស់រវើកនៅកម្ពុជា។

## **ឯកសារយោង** (References)


Heng, K., & Heng, K. (2023). ការលើកកម្ពស់ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា៖ កាលានុវត្តភាព បញ្ហាប្រឈម និងអនុសាសន៍សម្រាប់គោលនយោបាយ [Promoting research in Cambodian higher education: Opportunities, challenges, and policy implications]. *Cambodian Journal of Education and STEM*, *1*(1), 93–104. https://doi.org/10.62219/cjes.2023118

Heng, K., Meas, S., & Heng, K. (2023). ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវដ៏រស់រវើកនៅកម្ពុជា៖ គំនិតផ្តួចផ្តើមថ្មីៗ និងទិសដៅនាពេលអនាគត [Developing a vibrant research ecosystem in Cambodia: Recent initiatives and future directions]. *Cambodian Journal of Education and STEM*, *1*(2), 81–104. https://doi.org/10.62219/cjes.2023127

Heng, K., Sok, S, & Heng, K. (2024). តួនាទីគោលនយោបាយស្រាវជ្រាវក្នុងការលើកកម្ពស់ការស្រាវជ្រាវនៅឧត្តមសិក្សា [The roles of research policies in promoting research in higher education]. *Cambodian Journal of Education and STEM*, *2*(1), 1–5. https://doi.org/10.62219/cjes.2024211